សុន្ទរកថារបស់ **លោក ទ៉ាដា តាកាយូគី**
លេខាទីពីរ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ
ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅអនុវិទ្យាល័យតាកែវ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង
ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**
**សូមគោរព ឯកឧត្តម អ៊ឹម កុច រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា!**
**សូមគោរព លោក ឡុង ផាត អភិបាលរងខេត្តព្រៃវែង!**
**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដើម្បីចូលរួមក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅអនុវិទ្យាល័យតាកែវនៅថ្ងៃនេះ ជាមួយនឹងវត្តមានរបស់ឯកឧត្តម អ៊ឹម កុច រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និង លោក ឡុង ផាត អភិបាលរងខេត្តព្រៃវែង។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡា និងជាពិសេស អង្គការ JHP ដែលបានសម្របសម្រួល និងអនុវត្តគម្រោងនេះ។

ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ បន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងកិច្ចកសាង និងអភិវឌ្ឍន៍ប្រទេសឡើងវិញ រហូតបានក្លាយជាប្រទេសមួយដែលមានអត្រាកំ ណើនសេដ្ឋកិច្ចខ្ពស់ក្នុងចំណោមបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចរីកចំរើនក្នុងតំបន់អាស៊ាន។ ជាមួយគ្នានេះផងដែរ វិស័យអប់រំបានបន្តរីកចំរើនទាំងបរិមាណ និងគុណភាពពីមួយឆ្នាំទៅមួយឆ្នាំ។

ខ្ញុំសូមធ្វើការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អវិស័យអប់រំ។ ដោយបានទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំ ថាជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តផ្ដល់ជំនួយឧបត្ថម្ភរបស់ខ្លួនដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា តាមរយៈការជួយសាងសង់សាលារៀន ក៏ដូចជាបណ្ដុះបណ្ដាលគ្រូបង្រៀនជាដើម។

ខ្ញុំបានទទួលដំណឹងថាសិស្សានុសិស្សប្រមាណ៤២នាក់ នៅអនុវិទ្យាល័យតាកែវត្រូវរៀននៅក្នុងថ្នាក់រៀនដែលគ្មានសុវត្ថិភាពដោយសារអគារសិក្សាភាគច្រើនបានបាក់បែក ចាស់ទ្រុឌទ្រោមនិងបញ្ហាកង្វះបន្ទប់រៀន។ចាប់ពីឆមាសក្រោយនេះតទៅ សិស្សានុសិស្សប្រមាណ ១២០នាក់ ដែលរាប់ទាំងសិស្សដែលមកពីសាលាផ្សេងទៀតនឹងចាប់ផ្ដើមរៀនសូត្រនៅក្នុងអគារសិក្សាថ្មីនេះ។

ឥឡូវនេះអគារសិក្សាថ្មីដែលសង់ខ្ពស់ផុតពីដីមាន៤បន្ទប់ និងបរិក្ខារអនាម័យដែលជាអគារសិក្សាទី៣ ក្រោមជំនួយឧបត្ថម្ភពីគម្រោងគូសាណូណិរបស់ជប៉ុនក្នុងខេត្តព្រៃវែងនេះ ត្រូវបានសាងសង់រួចរាល់ហើយ។ ដូច្នេះ ក្មួយៗសិស្សានុសិស្សទាំងអស់អាចសិក្សានៅក្នុងអគារសិក្សាថ្មីនេះដោយសុវត្ថិភាព និងជាសុខភាព ពិសេសនៅ រដូវភ្លៀង។

ខ្ញុំសង្ឃឹមថា សិស្សានុសិស្សនៃអនុវិទ្យាល័យតាកែវទាំងអស់នឹងរីករាយជាមួយការរៀនសូត្រនៅក្នុងថ្នាក់រៀនថ្មីដែលមានបរិស្ថានសិក្សាល្អប្រសើរនេះ ដូចនេះសូមជួយថែរក្សាអគារទាំងនេះ ឲ្យបាននៅគង់វង្សល្អ ទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំស ង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះនឹងជួយ ពង្រឹងជាបន្តទៅទៀត នូវទំនាក់ទំនងមិត្តភា ពរវាង ប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់!